**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៣ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមជំនួយការសម្រាប់ធ្វើការប្រមូលសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

www.pheakdeylaw.com

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមជំនួយការសម្រាប់ធ្វើការបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯ.ឧ លេង វី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២. **ឯ.ឧ ឌុច សុន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. **ឯ.ឧ អែវ ប៊ុនថុល** | អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងស៊ីវិល ក្រសួងមហាផ្ទៃ | សមាជិក |
| ៤. **ឯ.ឧ នាយឧត្តមសេនីយ៍ ម៉ៅ ច័ន្ទតារា** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៥. **ឯ.ឧ រាជ សុភទ្ទ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. **ឯ.ឧ រស់ វុណ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ២.-**

ក្រុមជំនួយការដូចមានចែងក្នុងប្រការ១ខាងលើ មានភារកិច្ចធ្វើជាសេនាធិការជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង** លើការងារសំខាន់ៗ ដូចខាងក្រោម៖

-ទទួលរបាយការណ៍ពីក្រុមការងារថ្នាក់ជាតិចុះរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបអំពីសកម្មភាពការងាររបស់ក្រុមការងារឲ្យបានទៀតទាត់ស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

-ធ្វើការបូសរុបវាយតម្លៃអំពីសមិទ្ធផលក្នុងសកម្មភាពការងារចុះជួយមូលដ្ឋាន និងការដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន។

-សហការជាមួយក្រុមការងារ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធសិក្សាអំពីក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងវិធានការក្នុងការដោះស្រាយបញ្ហាប្រឈម ដែលក្រុមការងារមិនអាចដោះស្រាយបាន ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល។

-សហការជាមួយក្រុមការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកសំណើពាក់ព័ន្ធការស្នើសុំកែសម្រួល ផ្លាស់ប្តូរ បំពេញបន្ថែមសមាសភាពក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន។

-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពី**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង**។

**ប្រការ៣.-**

ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២ ប្រធានក្រុមជំនួយការត្រូវសុំយោបល់ដឹកនាំជាប្រចាំពី**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង**។ ក្រុមជំនួយការមានសិទ្ធិចាត់ចែងមន្ត្រីតាមរង្គភាពសាមីឲ្យជួយការងារតាមការចាំបាច់។

ប្រធានក្រុមជំនួយការមានសិទ្ធិចាត់ចែងប្រគល់ភារកិច្ចដល់អនុប្រធាន និងសមាជិកក្រុមការងារ ព្រមទាំងកោះប្រជុំតាមការចាំបាច់។


www.pheakdeylaw.com

**ប្រការ៤.** _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

<u>កន្លែងទទួលៈ</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ*
*-ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នៅរាជធានី ខេត្តទាំងអស់*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-សាមីខ្លួនដូចមានចែងក្នុងប្រការ១*
*-ឯកសារ-កាលប្បវត្តិ*